01324588

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 02 / 2016
ម៉ោង (Time/Heure): 11:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E371/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សម្ងាត់ / Confidential / Confidentiel

**Declassified to Public**
**27 June 2019**

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **សំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យភាគីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ជុំវិញសំណើសុំស្តាប់សក្ខីកម្មលោកស្រី Ewa Tabeau**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយពីមេធាវីការពារក្តី នួន ជា និង សហព្រះរាជអាជ្ញា សុំស្តាប់សក្ខីកម្មលោកស្រី Ewa Tabeau អ្នកជំនាញផ្នែកប្រជាសាស្ត្រ។

២. មេធាវីការពារក្តី នួន ជា ស្នើសុំកោះហៅបណ្ឌិត Tabeau មកផ្តល់សក្ខីកម្ម ទាក់ទងនឹង "បញ្ហានានារួមមាន ចំនួន និង មូលហេតុនៃការស្លាប់មនុស្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" និង បានស្នើសុំស្តាប់សក្ខីកម្មរបស់គាត់នៅក្នុងអង្គហេតុស្តីពីការផ្លាស់ទីលំនៅប្រជាជន សហករណ៍ និង ការដ្ឋាន មន្ទីរសន្តិសុខ និង ការប្រព្រឹត្តចំពោះពុទ្ធសាសនិក ប្រជាជនចាម និង ប្រជាជនវៀតណាម (ឯកសារ E305/4.2 ទំព័រ ៤៩-៥១)។ សហព្រះរាជអាជ្ញាលើកឡើងថា សក្ខីកម្មរបស់បណ្ឌិត Tabeau ពាក់ព័ន្ធនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ការផ្លាស់ទីលំនៅប្រជាជន ការប្រព្រឹត្តចំពោះពុទ្ធសាសនិក ប្រជាជនចាម និង ប្រជាជនវៀតណាម (ឯកសារ

E305/6.4 ទំព័រ ៤៧ (ភាសាអង់គ្លេស))។

៣. នៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ នៅពេលអង្គជំនុំជម្រះស្តាប់សក្ខីកម្មលើអង្គហេតុស្តីពីការប្រព្រឹត្តិចំពោះប្រជាជនវៀតណាម មេធាវីការពារក្តី នួន ជា បានស្នើសុំពន្លឿនការស្តាប់សក្ខី-កម្មបណ្ឌិត Tabeau។ មេធាវីបានលើកឡើងថា "អង្គជំនុំជម្រះត្រូវស្តាប់សក្ខីកម្មរបស់ជនរងគ្រោះជាច្រើននាក់ ក៏ដូចជាផលប៉ះពាល់នៃបទឧក្រិដ្ឋដែលរងការចោទប្រកាន់ ថាបានប៉ះពាល់ដល់ប្រជាជនកម្ពុជាទាំងមូល និង ក្រុមជាក់លាក់មួយចំនួន ដូចជាជនជាតិចាម និង វៀតណាម" (ឯកសារ E371 កថាខណ្ឌ ៨)។ មេធាវីបានរម្លឹកថា សក្ខីកម្មរបស់បណ្ឌិត Tabeau ពាក់ព័ន្ធនឹងការប្រព្រឹត្តិទៅលើក្រុមជាតិពន្ធុ និង ក្រុមជនជាតិនានាក្នុងអំឡុងកម្ពុជាប្រជាធិប-តេយ្យ (ឯកសារ E371 កថាខណ្ឌ ៨)។

៤. នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានបដិសេធសំណើសុំពន្លឿនការកោះហៅបណ្ឌិត Tabeau មកផ្តល់សក្ខីកម្ម ដោយសន្និដ្ឋានថា មេធាវីការពារក្តី នួន ជា មិនបានផ្តល់សំអាងហេតុគួរឱ្យជឿជាក់បាន ថាមូលហេតុអ្វីត្រូវស្តាប់សក្ខីកម្មរបស់បណ្ឌិត Tabeau នៅពេលនេះ ជាជាងស្តាប់សក្ខីកម្មរបស់លោកស្រីនៅក្នុងអំឡុងពេលជំនុំជម្រះលើអង្គហេតុក្រោយៗទៀតនោះ។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ដែរថា អង្គជំនុំជម្រះមិនទាន់បានសម្រេចថា តើត្រូវកោះហៅ ឬ មិនកោះហៅបណ្ឌិត Tabeau មកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញទេ (ឯកសារ E371/1 កថាខណ្ឌ ៣)។

៥. អង្គជំនុំជម្រះកត់សម្គាល់ថា របាយការណ៍សំអាងទៅលើដីកាដំណោះស្រាយ ហើយនៅក្នុងបរិបទនៃការជំនុំជម្រះនេះ ភាគីជាអ្នកស្នើសុំ ជាចម្បងគឺដើម្បីបញ្ជាក់ពីការស្លាប់បន្ថែមនៃប្រជាជនវៀតណាម និង ប្រជាជនចាម (ដីកាដំណោះស្រាយ កថាខណ្ឌ ៧៤៧, ៧៩២-៧៩៣)។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមពីកម្រិតនៃភាពមិនច្បាស់លាស់ដែលជាមូលដ្ឋានទិន្នន័យជាក់លាក់នៅក្នុងរបាយការណ៍ នៅពេលអង្គជំនុំជម្រះយកអង្គហេតុនេះមកពិភាក្សា (របាយការណ៍ ទំព័រ ១០០-១០៥)។

៦. អង្គជំនុំជម្រះបានចាប់ផ្តើមទាក់ទងជាមួយបណ្ឌិត Tabeau តាមរយៈអង្គភាពគាំពារសាក្សី និង អ្នកជំនាញ (WESU) ដើម្បីកំណត់ថា តើលោកស្រីមានពេលទំនេរមកផ្តល់សក្ខីកម្មបាន

ទេ ក្នុងករណីដែលអង្គជំនុំជម្រះសម្រេចកោះហៅលោកស្រី។ បណ្ឌិត Tabeau បានគូសបញ្ជាក់ថា លោកស្រីបានរៀបរៀងរបាយការណ៍ ៨ ឆ្នាំមកហើយ និង បានស្នើសុំធ្វើបច្ចុប្បន្នភាពចំពោះរបាយការណ៍នេះ ដោយផ្អែកលើសម្ភារៈដែលអាចរកបាននាពេលថ្មីៗទៅលើបញ្ហានៃអង្គសេចក្តីនេះ ដោយបានវាយតម្លៃថា ដំណើរការនេះនឹងចំណាយពេលជាច្រើនខែ ហើយចាំបាច់ត្រូវធ្វើដំណើរមកកម្ពុជាម្តង ឬ ពីរដង។ អង្គជំនុំជម្រះក៏បានសាកសួរព័ត៌មានបន្ថែមទៀត ពាក់ព័ន្ធនឹងសម្ភារៈថ្មីៗដែលអាចរកបាន ទាក់ទិននឹងចំនួននៃការស្លាប់បន្ថែមនៃប្រជាជនវៀតណាម និង ប្រជាជនចាម។ បណ្ឌិត Tabeau បានឆ្លើយតបថា៖

> តាមដែលខ្ញុំយល់ សំណើសុំរបស់អង្គជំនុំជម្រះផ្តោតជាសំខាន់បំផុតទៅលើអត្ថិភាពនៃការកើនឡើងចំនួនអ្នកស្លាប់ដែលជាប្រជាជនវៀតណាម និង ប្រជាជនចាម។ ជាងនេះទៀត អង្គជំនុំជម្រះចង់ស្តាប់សក្ខីកម្មជាពិសេសថា តើព័ត៌មានផ្នែកស្ថិតិថ្មីអាចរកបានដែរ ឬ ទេ នៅក្នុងចិរវេលាចន្លោះពេលធ្វើជំរឿនឆ្នាំ ១៩៦២ ដល់ឆ្នាំ ១៩៩៨ ដែលនឹងអាចអនុញ្ញាតឱ្យបង្កើតបាននូវចំនួននៃការស្លាប់បន្ថែមនៃប្រជាជនវៀតណាម និង ប្រជាជនចាមដោយមានកម្រិតនៃភាពជាក់លាក់ជាងនៅក្នុងរបាយ-ការណ៍ដើមរបស់ខ្ញុំ។
>
> ចម្លើយរបស់ខ្ញុំចំពោះបញ្ហាខាងលើគឺថា ខ្ញុំពុំបានធ្វើការស្រាវជ្រាវឱ្យបានសកម្មក្នុងការស្វែងរកព័ត៌មានទាំងនេះទេ ហើយហេតុនេះ ខ្ញុំពុំដឹងទេ។ ខ្ញុំពុំបានដឹងថាមានព័ត៌មានថ្មីអំពីចំណុចនេះទេ។ ខ្ញុំក៏មានជំនឿថា ហាក់ដូចជាពុំទាន់មានព័ត៌មានថ្មីនៅក្នុងបរិបទជាក់លាក់នេះនៅឡើយទេ។
>
> ការពិត ខ្ញុំបានចង្អុលបង្ហាញនៅក្នុងអ៊ីមែលរបស់ខ្ញុំរួចហើយថា ខ្ញុំដឹងអំពីសម្ភារៈថ្មី និង សម្ភារៈបន្ថែមមួយចំនួនដែរ ដែលខ្ញុំបានចាប់អារម្មណ៍ ចាប់តាំងពីខ្ញុំបានបញ្ចប់របាយការណ៍ឆ្នាំ ២០០៦ របស់ខ្ញុំ។ ខ្ញុំសូមភ្ជាប់មកជាមួយនូវបញ្ជីនៃការបោះពុម្ពផ្សាយថ្មីៗ ដែលមិនត្រូវបានយកមកពិនិត្យនៅក្នុងរបាយការណ៍ឆ្នាំ ២០០៦ របស់ខ្ញុំ។ បញ្ជីនេះគឺមិនមែនជាផលិតផលនៃការសិក្សាពិនិត្យជាប្រព័ន្ធទៅលើសម្ភារៈថ្មីៗដែលមានស្រាប់ទេ វាគ្រាន់តែជាផលិតផលបន្ទាប់បន្សំនៃការស្រាវជ្រាវរបស់ខ្ញុំតាមប្រព័ន្ធអ៊ិនធឺណេតប៉ុណ្ណោះ។ បញ្ជីនេះពាក់ព័ន្ធនឹងទំហំ និង គំរូទូទៅនៃការធ្វើឱ្យទៅជាជនរងគ្រោះ ដែលចំណុចមួយចំនួនបានពិភាក្សាអំពីវិធីសាស្ត្រចុងក្រោយបំផុតដែលយកមកប្រើប្រាស់ ប៉ុន្តែវាពុំមែនជាការរាយការណ៍អំពីជនជាតិភាគតិចវៀត-

ណាម និង ចាម ឡើយ។ អត្ថបទឆ្នាំ ២០១៥ របស់ Heuveline ក៏ពុំមែនជាការរាយការណ៍អំពីជនជាតិភាគតិចដែរ។ ហេតុនេះ ចំណុចនេះពុំពាក់ព័ន្ធទៅនឹងសំណួរដែលអង្គជំនុំជម្រះបានសាកសួរនោះទេ។

៧. អង្គជំនុំជម្រះសូមភ្ជាប់មកជាមួយនូវបញ្ជីនៃការបោះពុម្ពផ្សាយដែលបណ្ឌិត Tabeau បានដាក់ជូន។

៨. ដោយពិចារណាដល់ភាពចាំបាច់ក្នុងការស្រាវជ្រាវបន្ថែម ដែលអាចចំណាយពេលជាច្រើនខែទៅតាមសំណើរបស់អ្នកជំនាញ ជាលក្ខខណ្ឌមួយដែលលោកស្រីទាមទារមុនមកផ្តល់សក្ខីកម្ម និង ការណ៍ដែលថា ការធ្វើសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍ស្តីអំពីចំនួនសរុបនៃការស្លាប់ជាទូទៅ និង ជាពិសេស ស្តីអំពីការស្លាប់ជនជាតិភាគតិចបន្ថែម អាចមានភាពមិនច្បាស់លាស់កម្រិតខ្ពស់ ដោយសារពុំមានទិន្នន័យដែលអាចរកបាន ដើម្បីបន្ថែមទៅលើជំរឿនឆ្នាំ ១៩៦២ និង ឆ្នាំ ១៩៩៨ នោះ អង្គជំនុំជម្រះសូមអញ្ជើញភាគីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ចំពោះសំណួរពីរដូចខាងក្រោម៖

ក. តើមេធាវីការពារក្តី នួន ជា និង សហព្រះរាជអាជ្ញានៅតែរក្សាសំណើរបស់ខ្លួនសុំស្តាប់សក្ខីកម្មរបស់លោកស្រីដដែល ឬ យ៉ាងណា?

ខ. ប្រសិនបើលោក/លោកស្រីនៅតែរក្សាសំណើសុំដដែល តើលោក/លោកស្រីស្នើសុំស្តាប់សក្ខីកម្មរបស់បណ្ឌិត Tabeau ទៅលើអង្គហេតុជាក់លាក់អ្វីខ្លះ? ដោយសារមានភាពពុំច្បាស់លាស់អំពីតួលេខនៅក្នុងរបាយការណ៍ សូមមេត្តាបញ្ជាក់ឲ្យច្បាស់ថា តើសក្ខីកម្មរបស់អ្នកជំនាញសមស្របសម្រាប់បញ្ជាក់អង្គហេតុទាំងនេះដោយរបៀបណា (វិធាន ៨៧(៣)(គ) នៃវិធានផ្ទៃក្នុង)។

៩. អង្គជំនុំជម្រះនឹងជូនដំណឹងដល់ភាគីអំពីពេលវេលាដែលភាគីត្រូវធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទៅតាមពេលវេលាសមស្រប។